01038595

E320/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 21 / 11 / 2014
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម Claudia FENZ |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | សាធារណៈ |

**សេចក្តីសម្រេចស្តីពីការតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការសម្រាប់**

**ខៀវ សំផន**

**សហព្រះរាជអាជ្ញា**

ជា លាង

Nicholas KOUMJIAN

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Marie GIRAUD

**ជនជាប់ចោទ**

នួន ជា

ខៀវ សំផន

**មេធាវីជនជាប់ចោទ**

សុន អរុណ

Victor KOPPE

គង់ សំអុន

Arthur VERCKEN
Anta GUISSÉ

01038596

E320/2

## ១. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១. អង្គជំនុំជម្រះកំពុងប្រឈមនឹងការបដិសេធរបស់មេធាវីការពារក្តី ខៀវ សំផន មិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ អនុលោមតាមការណែនាំរបស់ជនជាប់ចោទ ក្នុងខណៈដែលពួកគាត់កំពុងធ្វើសេចក្តីព្រាងសារណាបណ្តឹងសាទុក្ខរបស់ខ្លួននៅក្នុងសំណុំរឿង ០០២/០១។

២. ក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការ នាថ្ងៃទី ១១ និង ១២ ខែ ធ្នូ ឆ្នាំ ២០១៣ មេធាវីការពារក្តីឲ្យ ខៀវ សំផន បានបង្ហាញទស្សនៈរបស់ខ្លួនជាថ្មីម្តងទៀតថា សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០២ មិនគួរចាប់ផ្តើមឡើយ រហូតដល់មានការវិនិច្ឆ័យជាស្ថាពរលើសំណុំរឿង ០០២/០១ រួមទាំងដំណើរការលើបណ្តឹងសាទុក្ខផងដែរ[1]។ នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ មេធាវីការពារក្តីបានដាក់សំណើមួយស្តីអំពីបញ្ហានេះ ដែលសំណើនោះត្រូវបានបដិសេធ នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤[2]។

៣. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ បន្ទាប់ពីមានការចេញសាលក្រមក្នុងសំណុំរឿង ០០២/០១ ខៀវ សំផន បានដាក់សំណើមួយទៀត ស្នើសុំឲ្យពន្យារពេលកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២ រហូតដល់មានការចេញសាលដីកា និងបណ្តឹងសាទុក្ខផ្សេងៗទៀត ទាក់ទងនឹងសំណុំរឿង ០០២/០១[3]។ អង្គជំនុំជម្រះបានបដិសេធសំណើនេះ នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ និងបានកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ នៅថ្ងៃទី ១៧

---

[1] ប្រតិចារិកសវនាការ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ ទំព័រ ១០៧ (ភាសាអង់គ្លេស)។ ប្រតិចារិកសវនាការ ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៣ ទំព័រ ៨៥ (ភាសាអង់គ្លេស)។

[2] សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ស្តីពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមស្ថាពរនៃសំណុំរឿង ០០២/០១ មុននឹងចាប់ផ្តើមសំណុំរឿង ០០២/០២ ឯកសារ E301/5/5 ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤។ សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្តើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ថាពរលើសំណុំរឿង ០០២/០១ ឯកសារ E301/5/5/1 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤។

[3] សំណើរបស់លោក ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឲ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ឯកសារ E314/1 ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ (“សំណើសុំផ្អាកកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២/០២ ឬបណ្តឹងជំទាស់ចៅក្រម”)។

01038597



ខែ តុលា ឆ្នាំ ២០១៤[4]។ នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៤ ខៀវ សំផន បានដាក់សំណើមួយ ស្នើសុំឲ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទរបស់អង្គជំនុំជម្រះ ដែលសំណើនេះត្រូវបានបដិសេធនៅថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤[5]។

៤. ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ខៀវ សំផន បានជម្រាបជូនអង្គជំនុំជម្រះថា គាត់បានណែនាំមេធាវីការពារក្តីរបស់គាត់ មិនឲ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២។ បន្ទាប់មក មេធាវីការពារក្តីបានចាកចេញពីបន្ទប់សវនាការ។ មេធាវីការពារក្តីឲ្យ ខៀវ សំផន បានលើកឡើងនូវហេតុផលមួយចំនួន រួមទាំងបញ្ហាធនធានផងដែរ ចំពោះការសម្រេចមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៤ ដែលក្នុងអំឡុងពេលនោះ អង្គជំនុំជម្រះបានជូនដំណឹងដល់គ្រប់ភាគីថា អង្គជំនុំជម្រះនឹងដោះស្រាយបញ្ហាធនធាន និងបញ្ហាពាក់ព័ន្ធនានាផងដែរ។

៥. ទោះបីជាមានការបង្គាប់ឲ្យចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការក៏ដោយ ក៏មេធាវីជាតិ និងមេធាវីអន្តរជាតិការពារក្តីឲ្យ ខៀវ សំផន មិនមានវត្តមាន ឬផ្តល់នូវយុត្តិកម្មត្រឹមត្រូវចំពោះការអវត្តមានរបស់ពួកគេឡើយ។ នៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានព្រមានជាផ្លូវការដល់មេធាវីការពារក្តីឲ្យ ខៀវ សំផន ចំពោះកំហុសវិជ្ជាជីវៈ អនុលោមតាមវិធាន ៣៨ នៃវិធានផ្ទៃក្នុង និងបានបង្គាប់ឲ្យភាគីទាំងអស់មានវត្តមាននៅក្នុងកិច្ចប្រជុំរៀបចំសវនាការបន្ថែម នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤[6]។

---

[4] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារការចាប់ផ្តើមសំណុំរឿង ០០២/០២ ឯកសារ E314/5 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចលើសំណើសុំពន្យារពេល")។ ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ឯកសារ E316 ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤។

[5] សំណើជាបន្ទាន់សុំឲ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ ឯកសារ E314/5/1 ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៤ ("សំណើរបស់ ខៀវ សំផន ទាក់ទងនឹងកាលបរិច្ឆេទសវនាការ")។ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សេចក្តីសម្រេចលើសំណើជាបន្ទាន់របស់ ខៀវ សំផន សុំឲ្យពិចារណាឡើងវិញលើដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២" ឯកសារ E314/5/3 ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៤។

[6] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "ការព្រមានមេធាវីការពារក្តី នួន ជា និង ខៀវ សំផន" ឯកសារ E320 ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៦ និង ៨។

៦. មេធាវីការពារក្ដីឱ្យ ខៀវ សំផន មានវត្តមាននៅក្នុងកិច្ចប្រជុំរៀបចំសវនាការនេះ និងបានធ្វើសេចក្ដីសន្និដ្ឋានបន្ថែម ទាក់ទងនឹងហេតុផលនៃការប្រព្រឹត្តរបស់ពួកគេ និងបានបញ្ជាក់អំពីចេតនាមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ទៀតឡើយ។ នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធសេចក្ដីសន្និដ្ឋានដែលបានលើកឡើងជាយុត្តិកម្មចំពោះការបដិសេធមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធី និងបានបង្គាប់ឱ្យភាគីទាំងអស់មានវត្តមាននៅក្នុងសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ដែលនឹងចាប់ផ្ដើមនៅថ្ងៃចន្ទ ទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ អង្គជំនុំជម្រះ បានជូនដំណឹងបន្ថែមទៀតដល់មេធាវីការពារក្ដីឱ្យ ខៀវ សំផន ឱ្យបានដឹងជាមុនថា អង្គជំនុំជម្រះនឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ប្រសិនបើមេធាវីការពារក្ដី ខកខានមិនបានគោរពតាមដីកាបង្គាប់ឱ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការខាងមុខនេះ[7]។

៧. នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ មេធាវីការពារក្ដីឱ្យ ខៀវ សំផន បានដាក់ "សារណាបញ្ជាក់អំពីគោលជំហរ" ទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ដែលនៅក្នុងសារណានោះ មេធាវីការពារក្ដីបានបញ្ជាក់អំពីការមិនយល់ស្របរបស់ខ្លួនជាមួយនឹងសំអាងហេតុ និងសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះ និងបានបញ្ជាក់ថា គោលជំហររបស់ ខៀវ សំផន នៅរក្សាដដែល ហើយថា មេធាវីការពារក្ដីនឹងមិនចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ឡើយ រហូតដល់សារណាលើបណ្ដឹងសាទុក្ខសំណុំរឿង ០០២/០១ បានដាក់រួចរាល់[8]។

៨. នៅសវនាការថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហមេធាវីជាតិ និងអន្តរជាតិការពារក្ដីឱ្យ ខៀវ សំផន មិនមានវត្តមាននៅក្នុងតុលាការឡើយ។ ជនជាប់ចោទ ខៀវ សំផន ដែលមានវត្តមាននៅពេលនោះ បានបញ្ជាក់ថា គាត់បានណែនាំមេធាវីការពារក្ដីរបស់គាត់ឱ្យផ្ដង់អារម្មណ៍ទៅលើបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ និងមិនឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ឡើយ។ គាត់បានអះអាងទៀតថា

---

[7] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើងថា "សេចក្ដីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤" ឯកសារ E320/1 ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

[8] គោលជំហររបស់លោក ខៀវ សំផន បន្ទាប់ពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង E320/1 ឯកសារ E320/1/1 ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("គោលជំហររបស់ ខៀវ សំផន") កថាខណ្ឌ ៤៦។

01038599



ទាំងខ្លួនគាត់ និងមេធាវីការពារក្តីរបស់គាត់ មិនមានធនធានគ្រប់គ្រាន់ដើម្បីធ្វើការទៅលើសំណុំរឿងទាំងពីរនេះ នៅក្នុងពេលតែមួយបានទេ[9]។

៩. អង្គជំនុំជម្រះបានណែនាំដល់ ខៀវ សំផន ថា សិទ្ធិរបស់គាត់ក្នុងការទទួលបានជំនួយពីមេធាវីតាមការជ្រើសរើសដោយខ្លួនឯងផ្ទាល់ មិនមានលក្ខណៈដាច់ខាតឡើយ ហើយថា អង្គជំនុំជម្រះអាចតែងតាំងមេធាវី ដែលផ្ទុយនឹងបំណងរបស់ជនជាប់ចោទបាន ប្រសិនបើផលប្រយោជន៍យុត្តិធម៌តម្រូវ។ អង្គជំនុំជម្រះបានបង្គាប់ឲ្យជនជាប់ចោទ ជូនដំណឹងដល់អង្គជំនុំជម្រះនៅត្រឹមម៉ោង ៤.៣០ នាទី រសៀល ថ្ងៃ អង្គារ ទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ថាតើជនជាប់ចោទបន្ត ឬមិនបន្តណែនាំដល់មេធាវីរបស់គាត់មិនឲ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការទៀត ដែរឬយ៉ាងណា។ អង្គជំនុំជម្រះបានជូនដំណឹងបន្ថែមទៀតដល់ជនជាប់ចោទឲ្យបានដឹងជាមុនថា អង្គជំនុំជម្រះអាចតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការ ប្រសិនបើនៅពេលនេះ ឬនៅពេលណាមួយក្នុងពេលខាងមុខ ជនជាប់ចោទណែនាំដល់មេធាវីមិនឲ្យចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២/០២ នោះ[10]។

១០. នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ជនជាប់ចោទបានជូនដំណឹងដល់អង្គជំនុំជម្រះ តាមរយៈអង្គភាពគាំពារការការពារក្តី ថា "គាត់នៅតែបន្តណែនាំដល់មេធាវីការពារក្តីរបស់គាត់ ឲ្យផ្តោតការយកចិត្តទុកដាក់ និងពេលវេលាទាំងអស់របស់ពួកគេ ទៅលើការរៀបចំសារណាលើបណ្តឹងសាទុក្ខរបស់គាត់ក្នុងសំណុំរឿង ០០២/០១ រហូតដល់កាលបរិច្ឆេទចុងក្រោយនៃការដាក់បណ្តឹងសាទុក្ខនេះ ដែលត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ និងចាប់ផ្តើមចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង ០០២/០២ ភ្លាមបន្ទាប់ពីពេលនោះទៅ"[11]។

## ២. **សំអាងហេតុ**

១១. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ទោះបីជាការផ្តោតការយកចិត្តទុកដាក់ទៅលើទឡ្ហីករណ៍របស់ ខៀវ សំផន មានការប្រែប្រួលក៏ដោយ ក៏ចំណុចស្នូលនៃទឡ្ហីករណ៍នោះនៅតែថា គាត់មិនមាន

[9] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (ពង្រាង) ទំព័រ ៨ (ភាសាអង់គ្លេស)។

[10] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (ពង្រាង) ទំព័រ ១០-១២, ១៤ (ភាសាអង់គ្លេស)។

[11] សេចក្តីរាយការណ៍របស់អង្គភាពគាំពារការការពារក្តី អំពីការពិគ្រោះយោបល់ជាមួយលោក ខៀវ សំផន ឯកសារ E320/1/2 ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៤។

01038600



ពេលវេលា និងធនធានគ្រប់គ្រាន់ដើម្បីចូលរួមដោយផ្ទាល់ និង/ឬតាមរយៈមេធាវីការពារក្តីរបស់គាត់ នៅក្នុងកិច្ចដំណើរការនីតិវិធីជំនុំជម្រះសំណុំរឿង០០២/០២ និងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង០០២/០១ នៅក្នុងពេលតំណាលគ្នានោះទេ[12]។

១២. ដើម្បីធានាឲ្យការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស អង្គជំនុំជម្រះមានកាតព្វកិច្ចធ្វើការពិចារណាពីផលប្រយោជន៍យុត្តិធម៌ទាំងមូល រួមទាំងផលប្រយោជន៍របស់ភាគីទាំងអស់[13]។ អង្គជំនុំជម្រះបានពិភាក្សាយ៉ាងម៉ត់ចត់ និងពិចារណាលើមធ្យោបាយនានាដែលមានជាស្រេចសម្រាប់ក្រុមមេធាវីការពារក្តីនីមួយៗ ព្រមទាំងការកម្រិតទៅលើការចូលរួមរបស់ជនជាប់ចោទក្នុងការរៀបចំសារណាលើបណ្តឹងសាទុក្ខ ដោយយកចិត្តទុកដាក់ទៅលើការពន្យារពេលកាលបរិច្ឆេទកំណត់ចុងក្រោយសម្រាប់ដាក់សារណា ដែលអង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតឲ្យ[14]។ ទោះបីជា ការណែនាំរបស់ ខៀវ សំផន ទៅមេធាវីការពារក្តី អាចឆ្លុះបញ្ចាំងពីយុទ្ធសាស្ត្រនៃការការពារក្តីរបស់គាត់ក៏ដោយ ក៏គាត់មិនបានធ្វើការពិចារណាដល់ផលប្រយោជន៍យុត្តិធម៌ទាំងមូល និងមិនបានអើពើចំពោះវិធានការទាំងឡាយ ដែលអង្គជំនុំជម្រះបានដាក់ចេញដើម្បីដោះស្រាយកង្វល់នានារបស់គាត់នោះទេ ក្នុងនោះមាន ការកាត់បន្ថយចំនួនថ្ងៃធ្វើសវនាការក្នុងមួយសប្តាហ៍ និងការស្នើសុំទៅការិយាល័យរដ្ឋបាល ឲ្យផ្តល់ការគាំទ្របន្ថែមដើម្បីបង្កើនសមត្ថភាពការងាររបស់ក្រុមមេធាវីការពារក្តី[15]។

១៣. លើសពីនេះទៅទៀត ទោះបីជាមានការអះអាងពីការមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីចូលរួមក្នុងការជំនុំជម្រះក្តី និងការផ្តល់អាទិភាពលើកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខយ៉ាងណាក្តី ក៏ក្រុមមេធាវីការពារក្តីឲ្យ ខៀវ សំផន បានដាក់សំណើសុំពីរ ក្នុងសំណុំរឿង ០០២/០២ កាលពីថ្ងៃទី ១១ និងថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ដែលមិនមានអ្វីបន្ទាន់ ឬចាំបាច់ទាល់តែសោះ នៅ

---

[12] គោលជំហររបស់ ខៀវ សំផន កថាខណ្ឌ ១៦។ ប្រតិចារិកសវនាការ ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ (ពង្រាង) ទំព័រ ៨ (ភាសាអង់គ្លេស)។ សំណើរបស់ ខៀវ សំផន ទាក់ទងនឹងកាលបរិច្ឆេទសវនាការ។ ប្រតិចារិកសវនាការ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (ពង្រាងភាសាបារាំង) ទំព័រ ៨, ១៣-១៧។

[13] សេចក្តីសម្រេចលើសំណើសុំពន្យារពេល។

[14] សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤។

[15] សេចក្តីសម្រេចបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការកាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ៧។

ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ[16]។ ការដាក់សំណើនេះ មិនបានបន្ថែមទម្ងន់លើយុត្តិកម្ម ចំពោះការមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសំណុំរឿង០០២/០២ នោះទេ។ ក្រុមមេធាវីការពារក្តីឱ្យ នួន ជា ដែលស្ថិតនៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នានេះ បានប្រកាសថា ពួកគេបានត្រៀមខ្លួនរួចជាស្រេចដើម្បីចាប់ផ្តើមការជំនុំជម្រះក្តីវគ្គទីពីរ "តាំងពីខែមីនា ឆ្នាំ ២០១៤" មកម្ល៉េះ[17]។ នៅចំពោះមុខការពិតនេះ ក្រុមមេធាវីការពារក្តីឱ្យ ខៀវ សំផន លើកឡើងពី "យុទ្ធសាស្ត្រផ្សេងៗគ្នា" របស់ក្រុមមេធាវីការពារក្តីនីមួយៗ[18]។ នៅក្នុងការយល់ឃើញរបស់អង្គជំនុំជម្រះ ស្ថានភាពនេះនាំឱ្យមានចម្ងល់ទៅលើអាទិភាពដែលបានប្រកាសដោយជនជាប់ចោទ និងមូលហេតុដែលគាត់បានណែនាំដល់មេធាវីការពារក្តីរបស់គាត់បែបនោះ។

១៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញថា មេធាវីការពារក្តីកំពុងទាញយុត្តិកម្មសម្រាប់ការប្រព្រឹត្តរបស់ខ្លួន ដែលរួមមានទាំងការមិនគោរពតាមសេចក្តីសម្រេចនានារបស់អង្គជំនុំជម្រះ និងការរំលោភទៅលើដីកាបង្គាប់របស់តុលាការ ដោយឈរលើមូលដ្ឋាននៃការណែនាំរបស់កូនក្តីខ្លួន។ ការធ្វើយុត្តិកម្មបែបនេះ មិនអាចត្រូវបានប្រើប្រាស់ដោយមេធាវីដែលចាត់តាំងដោយតុលាការ និងទទួលការណែនាំ ដើម្បីផលប្រយោជន៍យុត្តិធម៌ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីជួយដល់ជនជាប់ចោទនោះទេ។

១៥. វិធាននីតិវិធីកម្ពុជាមិនមានចែងដោយផ្ទាល់ពីស្ថានភាពបែបនេះនោះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះធ្វើការយោងទៅលើវិធាននីតិវិធីដែលធ្លាប់អនុវត្តរួចហើយនៅកម្រិតអន្តរជាតិ[19]។ ទម្លាប់អនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានាបង្ហាញយ៉ាងច្បាស់ថា នៅពេលដែលជនជាប់ចោទជ្រើសរើសក្នុងការប្រើប្រាស់សិទ្ធិទទួលបានមេធាវីការពារក្តី ធ្វើឱ្យមានការរាំងស្ទះដល់កិច្ចដំណើរការជំនុំជម្រះ តុលាការមានឆន្ទានុសិទ្ធិក្នុងការចាត់តាំងមេធាវីដើម្បីជួយដល់ជនជាប់ចោទនោះ[20]។ ការធ្វើ

[16] សំណើសុំបញ្ចូលឯកសារថ្មីរបស់លោក ខៀវ សំផន ក្នុងកិច្ចពិភាក្សាដេញដោល (លិខិតរបស់ 2-TCE-81) ឯកសារ E324 ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៤។ គោលជំហររបស់ ខៀវ សំផន។

[17] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (សាធារណៈ) ទំព័រ ៣៦។

[18] ប្រតិចារឹកសវនាការ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ (សាធារណៈ) ទំព័រ ១៩។

[19] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៣៣(ថ្មី)។

[20] *ឧទាហរណ៍ សូមមើល រដ្ឋអាជ្ញា តទល់នឹង Milošević* អង្គជំនុំជម្រះតុលាការកំពូល ICTY (IT-02-54-AR73.7) សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើការតែងតាំងមេធាវីការពារក្តី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ("សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់*Milošević*")។ *រដ្ឋអាជ្ញា តទល់នឹង Milošević* អង្គជំនុំជម្រះសាលាដំបូង ICTY សេចក្តីសម្រេចស្តីពីការតែងតាំងមេធាវីដែលចាត់តាំងដោយតុលាការ/សាធារណៈ/ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤

ដូច្នេះ អង្គជំនុំជម្រះត្រូវតែថ្លឹងថ្លែងរវាងសិទ្ធិរបស់ជនជាប់ចោទក្នុងការជ្រើសរើស និងណែនាំដល់មេធាវីដែលខ្លួនបានជ្រើសរើស ជាមួយនឹងផលប្រយោជន៍យុត្តិធម៌នៅក្នុងកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និង ឆាប់រហ័ស[21]។

១៦. ការខកខានរបស់មេធាវី ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីសវនាការក្នុងសំណុំរឿង០០២/០២ តាមការណែនាំរបស់ ខៀវ សំផន គឺជាការរាំង ដល់ការជំនុំជម្រះឱ្យបានត្រឹមត្រូវ និងឆាប់រហ័សយ៉ាងពិតប្រាកដ។ ការជំនុំជម្រះ ត្រូវបានពន្យារពេលតាំងពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤។ ឥឡូវនេះ មេធាវីការពារក្តីឱ្យ ខៀវ សំផន ទាមទារឱ្យមានការពន្យារពេលបន្ថែមទៀតរហូតដល់ខែមករា ឆ្នាំ ២០១៥ ដែលប្រការនេះបង្កឱ្យមានការលំបាកសម្រាប់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ផលវិបាកផ្សេងៗ និងការចំណាយបន្ថែមសម្រាប់ភាគី និង អ.វ.ត.ក។ ដោយផ្អែកទៅលើទង្វើ និងសេចក្តីបញ្ជាក់នានាកាលពីពេលមុន អង្គជំនុំជម្រះយល់ឃើញថា ប្រសិនបើគ្មានវិធានការជាក់លាក់ទេនោះ មេធាវីបច្ចុប្បន្ននេះនឹងបន្តពឹងផ្អែកទៅលើការណែនាំពី ខៀវ សំផន ដើម្បីបង្កការរាំងស្ទះកិច្ចដំណើរការនីតិវិធីនៅពេលអនាគតទៀត។

១៧. អង្គជំនុំជម្រះយល់ឃើញថា ការរក្សាទុកមេធាវីបច្ចុប្បន្ន ដោយចាត់តាំងពួកគាត់ឱ្យធ្វើជាមេធាវីដែលចាត់តាំងដោយតុលាការ ប៉ុន្តែមិនឱ្យពួកគាត់គោរពតាមការណែនាំរបស់ជនជាប់ចោទមិនឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ដែលជាការកំហិតដែលប៉ះពាល់តិចតួចបំផុតដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការជ្រើសរើសមេធាវីដែលអាចចូលរួមសវនាការបាន។ អង្គជំនុំជម្រះយល់ឃើញ

---

(IT-01-54-T) សំអាងហេតុនៃសេចក្តីសម្រេចលើការតែងតាំងមេធាវីការពារក្តី ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៤។ *រដ្ឋអាជ្ញា តទល់នឹង Šešelj* អង្គជំនុំជម្រះសាលាដំបូង ICTY (IT-03-67-PT) សេចក្តីសម្រេចទៅលើបណ្តឹងរបស់រដ្ឋអាជ្ញាសុំឱ្យចេញសេចក្តីបង្គាប់តែងតាំងមេធាវីដើម្បីជួយ Vojislav Šešelj ក្នុងការការពារក្តីគាត់ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៣ ។ *រដ្ឋអាជ្ញា តទល់នឹង Karadžić* អង្គជំនុំជម្រះសាលាដំបូង ICTY (IT-95-5/18-T) សេចក្តីសម្រេចទៅលើការតែងតាំងមេធាវី និងសេចក្តីបង្គាប់ចំពោះកិច្ចដំណើរការនីតិវិធីជំនុំជម្រះជាបន្តទៅទៀត ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩។ *រដ្ឋអាជ្ញា តទល់នឹង Norman និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះសាលាដំបូង SCSL-04-14-T សេចក្តីបង្គាប់សំខាន់ចំពោះការតែងតាំង និងតួនាទីរបស់មេធាវីបម្រុង ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០០៤។

[21] រឿងក្តី *Milošević ទល់នឹង រដ្ឋអាជ្ញា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ* ICTY IT-02-54-AR73.7 សាលដីកាលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្អំប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីអំពីការចាត់តាំងមេធាវីការពារក្តី ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៤ កថាខណ្ឌ ១៣, ១៧។

ទៀតថា ប្រការនេះមានលក្ខណៈសមាមាត្រទៅនឹងគោលបំណងក្នុងការសម្រេចឱ្យបាននូវកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងឆាប់រហ័ស។

១៨. មេធាវីដែលចាត់តាំងដោយតុលាការ ក៏ដូចជាមេធាវីដែលបំពេញវិជ្ជាជីវៈទូទៅដែរ គឺមាន "កាតព្វកិច្ចក្នុងការលើកកម្ពស់យុត្តិធម៌ និងកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព និងត្រឹមត្រូវ" ហើយមេធាវីរូបនោះត្រូវតែបំពេញភារកិច្ចរបស់ខ្លួនឱ្យអស់ពីសមត្ថភាព ដើម្បីការពារផលប្រយោជន៍របស់ជនជាប់ចោទ[22]។ មេធាវីដែលចាត់តាំងដោយតុលាការអាចមិនធ្វើតាមការណែនាំរបស់កូនក្តីខ្លួន នៅពេលណាការណែនាំនោះនាំឱ្យ ឬធ្វើឱ្យរាំងស្ទះដល់កិច្ចដំណើរការនីតិវិធី ឬមិនស្របទៅនឹងផលប្រយោជន៍យុត្តិធម៌[23]។ មេធាវីរូបនោះត្រូវតែចូលរួមដោយមានប្រសិទ្ធភាពក្នុងសំណុំរឿង ០០២/០២ រួមទាំងការចូលរួមនៅគ្រប់កិច្ចដំណើរការនីតិវិធីរបស់តុលាការ និងមិនចាំបាច់ធ្វើតាមការណែនាំពីកូនក្តីរបស់ខ្លួនមិនឱ្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការនោះឡើយ។

១៩. ដោយសារមេធាវីបានស្គាល់សំណុំរឿងអស់ហើយ ការចាត់តាំងមេធាវីបច្ចុប្បន្នជាមេធាវីចាត់តាំងដោយតុលាការគឺជាជម្រើសជាក់ស្តែងបំផុតសម្រាប់ពេលនេះ។

**ផ្អែកតាមសម្អាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**សម្រេចចាត់តាំង** មេធាវី គង់ សំអុន មេធាវី Arthur VERCKEN និង មេធាវី Anta GUISSE ជាមេធាវីចាត់តាំងដោយតុលាការ សម្រាប់ការពារក្តីឱ្យ ខៀវ សំផន ចាប់ពីពេលនេះតទៅ។

**បង្គាប់ឱ្យ** មេធាវីខាងលើត្រូវចូលរួមនៅក្នុងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២/០២ នៅថ្ងៃ ចន្ទ ទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤ នៅវេលាម៉ោង ៩ ព្រឹកជាកំហិត និង

---

[22] វិធាន ២២(៤) នៃវិធានផ្ទៃក្នុង។

[23] *រដ្ឋអាជ្ញា តទល់នឹង Barayagwiza* សេចក្តីសម្រេចចំពោះសំណើរបស់មេធាវីការពារក្តីសុំដកខ្លួន ICTR-97-19-T ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០០ កថាខណ្ឌ ២៤ (ក្នុងករណីជនជាប់ចោទណែនាំឱ្យមេធាវីរបស់គាត់មិនតំណាងឱ្យគាត់នៅក្នុងសវនាការជំនុំជម្រះ "(មេធាវី) មិនអាចគ្រាន់តែធ្វើតាម "ការណែនាំ" របស់គាត់មិនឱ្យតំណាងគាត់នោះទេ។ ជាយោបល់របស់អង្គជំនុំជម្រះ ការណែនាំបែបនេះគួរតែចាត់ទុកថាជាការព្យាយាមធ្វើឱ្យរាំងស្ទះដល់ដំណើរការនីតិវិធីតុលាការ។ នៅក្នុងស្ថានភាពនេះ ការទាញទឡ្ហីករណ៍ថាមេធាវីមានកាតព្វកិច្ចធ្វើតាមការណែនាំនោះ ហើយថាការមិនធ្វើតាមការណែនាំនោះនឹងធ្វើឱ្យមានមូលដ្ឋានដើម្បីដកខ្លួន មិនមែនជាការត្រឹមត្រូវទេ")។

**បញ្ជាក់ឡើងវិញ** ពីចេតនារបស់អង្គជំនុំជម្រះ ក្នុងការបន្តនីតិវិធី តាមសេចក្ដីប្រកាសរបស់ប្រធានអង្គជំនុំជម្រះ កាលពីថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ប្រសិនបើមេធាវីការពារក្ដី អវត្តមានដោយមិនមានមូលហេតុសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៤

**ជ.ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE DE PREMIÈRE INSTANCE

**យ៉ា សុខន**